ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២៦៥៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង្ហាញខ្លួនរបស់បេក្ខជនទាំងពីរភេទ ក្របខ័ណ្ឌ "ក" និង "ខ" ដែលបានប្រឡងជាប់ជាស្ថាពរចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដល់បេក្ខជនទាំងពីរភេទ ក្របខ័ណ្ឌ "ក" និង "ខ" ដែលបានប្រឡងជាប់ជាស្ថាពរចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ នាសម័យប្រឡងថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០១៤ មណ្ឌលប្រឡងវិទ្យាល័យព្រះស៊ីសុវត្ថិមេត្តា ជ្រាបថា÷ បេក្ខជនត្រូវមកបង្ហាញខ្លួន ស្កេនម្រាមដៃ និងបំពេញបែបបទចូលបម្រើការងារ **ចាប់ពីថ្ងៃប្រកាសលទ្ធផលប្រឡងរហូតដល់ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៤** រៀងរាល់ម៉ោងធ្វើការ÷

- ពេលព្រឹក : ម៉ោង ០៧.០០ ដល់ ម៉ោង ១១.៣០
- ពេលរសៀល : ម៉ោង ១៤.០០ ដល់ ម៉ោង ១៧.៣០
- ទីកន្លែង : អគារសាលាជាតិពន្ធដារ ជាន់ទី ៨ ។

ក្នុងករណីខកខានមិនបានមកបង្ហាញខ្លួនតាមកាលកំណត់ខាងលើ អគ្គនាយកដ្ឋានពន្ធដារចាត់ទុកថា បេក្ខជនបោះបង់ចោលការងារ ហើយត្រូវបានលុបឈ្មោះចេញដោយស្វ័យប្រវត្តិ ។

អាស្រ័យហេតុនេះ សូមបេក្ខជនដែលប្រឡងជាប់ជាស្ថាពរចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារទាំងអស់ មេត្តាមកបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលបានកំណត់កុំបីខាន ។

អាសយដ្ឋានសាលាជាតិពន្ធដារ÷ អគារលេខ៤១-៤៣ ផ្លូវលេខ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

ទំនាក់ទំនង ÷
ទូរស័ព្ទលេខ: -០២៣ ៨៨១ ៩១០
-០១២ ៦៦៧ ១៨៨
-០១៧ ៣១៣ ៣៦៥
Email: nts@tax.gov.kh